ASEAN
AUSTRALIA
SMART CITIES
TRUST FUND
Asian Development Bank

Australian Government
Department of Foreign Affairs and Trade

ADB



# មូលនិធិទីក្រុងឆ្លាតវៃ អាស៊ាន អូស្ត្រាលី - ច្រកចូលទៅរកកិច្ចសហប្រតិបត្តិការ

SCAN FOR
DIGITAL VERSION

bit.ly/2X18e2x

មូលនិធិទីក្រុងឆ្លាតវៃ អាស៊ាន អូស្ត្រាលី (AASCTF) ផ្តល់ទំនាក់ទំនង កិច្ចសហប្រតិបត្តិការដល់អ្នករៀបចំក្រុង ឬ អ្នកគ្រប់គ្រងទទួលបន្ទុកសេវាកម្មសាធារណៈទីក្រុង ដើម្បីជួយឱ្យសម្រេចបាននូវរបៀបវារៈទីក្រុងឆ្លាតវៃនៃរដ្ឋបាលមូលដ្ឋានរបស់លោកអ្នក។
AASCTF ផ្តល់នូវការគាំទ្រ និងជំនាញបច្ចេកទេសដើម្បីសម្របសម្រួលដល់គម្រោងសាកល្បងនៃដំណោះស្រាយឌីជីថលឆ្លាតវៃ សម្របសម្រួលដល់ព្រឹត្តិការណ៍ចែករំលែកចំណេះដឹង និង ឱកាសកសាងសមត្ថភាព។

## តើទីក្រុងអាចទទួលបានអត្ថប្រយោជន៍អ្វីខ្លះពីមូលនិធិក្រុងឆ្លាតវៃនេះ ?

តាមរយៈមូលនិធិគាំទ្រនេះ មន្ត្រីរដ្ឋបាលមូលដ្ឋានដែលមកពីក្រុងសាល្បងនៃ AASCTF ក្លាយជាផ្នែកនៃប្រព័ន្ធដៃគូមួយដែលបានប្តេជ្ញាក្នុងការអភិវឌ្ឍ និងចែករំលែកការអនុវត្តល្អ ដំណោះស្រាយ និងគំនិតឆ្លាតវៃសម្រាប់ទីក្រុង ី ASEAN ដើម្បីប្រែក្លាយជាទីក្រុងដែលមានភាពទាក់ទាញ រស់នៅប្រកបដោយផាសុកភាព និងធន់មាំ។ ទីក្រុងដែលចូលរួមនឹងត្រូវអញ្ជើញចូលរួមប្រជុំតាមប្រព័ន្ធអនឡាញទំនើប ី (WEBINARS) និង វគ្គបណ្តុះបណ្តាល សិក្ខាសាលាតម្រង់ទិសនានាលើប្រធានបទជាក់លាក់ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍទីក្រុងឆ្លាតវៃ។
ជាងនេះទៀត មូលនិធិផ្តល់នូវវេទិកាអនឡាញដែលទីក្រុងនីមួយអាចចែករំលែកកិច្ចការប្រឈម និងដំណោះស្រាយនានាជាមួយដៃគូ និង ទទួលបានការគាំទ្រពីអ្នកជំនាញល្បីៗលើទិដ្ឋភាពផ្សេងៗ ក្នុងការរចនានិងរៀបចំគម្រោងសាកល្បង និងបង្ហាញគម្រោងនានា។



# សកម្មភាពបណ្តាញការងារ



ជាមួយគោលបំណងធំមួយដើម្បីចែករំលែកចំណេះដឹង ការរៀនសូត្របទពិសោធន៍ និង គំនិតថ្មីៗ AASCTF ប្រមូលផ្តុំដៃគូឯកជន និង សាធារណៈពីទីក្រុងនានានៃបណ្តាប្រទេសអាស៊ាន ដើម្បីចូលរួមក្នុងឱកាសរៀបចំបណ្តាញការងារទូលំទូលាយមួយ។ ដោយបានសម្របយ៉ាងជិតស្និទ្ធទៅនឹងផ្នែកសំខាន់ទាំងបីនៃមូលនិធិគាំទ្រនេះ សកម្មភាពបណ្តាញការងារស្វះស្វែងពង្រឹងកិច្ចសហប្រតិបត្តិការ កសាងសមត្ថភាព សម្របសម្រួលការផ្ទេរចំណេះដឹង និង បង្កើនការគិតគូរជាប្រព័ន្ធគ្រប់ជ្រុងជ្រោយ

**សម្របតាមផ្នែកបំពេញមុខងារគន្លឹះនៃ AASCTF**




## លទ្ធផលរំពឹងទុកសម្រាប់ការគ្រប់គ្រងការរៀបចំបណ្តាញ



| | | | | | |
|---|---|---|---|---|---|
| ការកសាង<br>សមត្ថភាព | ការផ្ទេរនូវ<br>ការអនុវត្តល្អបំផុត | ការកសាង<br>ទំនាក់ទំនង | បណ្តាញ<br>ទូលំទូលាយ | ពង្រឹកការគិតគូរ<br>គ្រប់ជ្រុងជ្រោយ | ស្វែងយល់ពីវប្បធម៌<br>ចម្រុះ |

### តើមានអ្វីនៅក្នុងបណ្តាញសម្រាប់ទីក្រុង?

តាមរយៈសកម្មភាពបណ្តាញ ទីក្រុងដែលចូលរួមនឹង៖

- អភិវឌ្ឍជំនាញកិច្ចសហប្រតិបត្តិការអន្តរវប្បធម៌ និង ទំនាក់ទំនង
- បង្កើនការស្វែងយល់ពីភាពស្មុគស្មាញនៃការអភិវឌ្ឍទីក្រុងឆ្លាតវៃ
- ទទួលបទពិសោធន៍ពីអន្តរជាតិ និង
- ស្វែងរកទីផ្សារ និងឱកាសថ្មីៗ

### តើសកម្មភាពបណ្តាញពាក់ព័ន្ធនឹងអ្វីខ្លះ?

សកម្មភាពបណ្តាញ AASCTF ផ្តោតលើក្រុមដៃគូធំមួយមកពីវិស័យសាធារណៈ ឯកជន និង អង្គការមិនមែនរដ្ឋាភិបាល និង អង្គការមិនរកប្រាក់ចំណេញ។ មូលនិធិមានគោលបំណងបង្កើតការផ្លាស់ប្តូរនូវគំនិតទស្សនៈដែលគួរចាប់អារម្មណ៍ និង ការអនុវត្តល្អៗរវាងទីក្រុងនិងទីក្រុង លើផ្នែកផ្សេងៗដែលទាក់ទងទៅនឹងការអភិវឌ្ឍទីក្រុងឆ្លាតវៃ ការកសាងភាពជាដៃគូរវាងឯកជន និងរដ្ឋ និង បញ្ហាពាក់ព័ន្ធគ្នាសំខាន់ៗផ្សេងទៀត ក្នុងនោះមាន៖ ការរួមបញ្ចូលផ្នែកសង្គម សមភាពយេនឌ័រ និងការលើកកម្ពស់សិទ្ធិអំណាចស្ត្រី ភាពធន់នឹងបម្រែបម្រួលអាកាសធាតុ និង និរន្តរភាពបរិស្ថាន។

### តើដំណើការរៀបចំបណ្តាញប្រព្រឹត្តទៅបែបណា?

| ខែ ១-២ | ខែ ២-៤ | ខែ ៤ បន្តទៅមុខ |
|---|---|---|
| AASCTF នឹងធ្វើការអង្កេតវាយតម្លៃពីតម្រូវការដើម្បីកំណត់នូវភាពប្រឈមនឹងប្រព័ន្ធឌីជីថល និង អាទិភាពនៃទីក្រុងឆ្លាតវៃ។ ការអង្កេតនេះនឹងធ្វើឡើងជាភាសាក្នុងស្រុកនៃទីក្រុងនោះ។ | អ្នកពាក់ព័ន្ធមកពីទីក្រុងដែលបានជ្រើសរើសនឹងត្រូវអញ្ជើញចូលរួមក្នុង វគ្គបណ្តុះបណ្តាលណែនាំស្តីពីទីក្រុងឆ្លាតវៃ និង សិក្ខាសាលាផ្សេងទៀត ដើម្បីកំណត់នូវភាពប្រឈមផ្នែកឌីជីថល និង ចំណាប់អារម្មណ៍ផ្សេងៗ។ | គេនឹងអញ្ជើញអ្នកពាក់ព័ន្ធមកពីទីក្រុងដែលបានជ្រើសរើសចូលរួមក្នុងសិក្ខាសាលា/ ជំនួបតាមអនឡាញលើប្រធានបទពាក់ព័ន្ធវិស័យនានា |

### ចូលរួមក្នុងបណ្តាញទីក្រុងឆ្លាតវៃ AASCTF

AASCTF សូមស្វាគមន៍ទីក្រុងនានាពីប្រទេសក្នុងតំបន់អាស៊ានដែលមានចំណាប់អារម្មណ៍ចូលរួមក្នុងសកម្មភាពបណ្តាញរបស់យើង។ ទីក្រុងនានាអាចផ្ញើអ៊ីមែលមកកាន់ aasctf@adb.org ឬ ស្កេនកូដ QR នៅខាងស្តាំ ដើម្បីបំពេញសំណុំបែបបទតាមអនឡាញមួយ។ សូមតាមដានបណ្តាញសង្គមរបស់យើងដើម្បីទទួលបានព័ត៌មានថ្មីៗស្តីពី ព្រឹត្តិការណ៍ផ្សេងៗ របស់ AASCTF ។

eepurl.com/g_U7ZD

AASCTF | bit.ly/30zLuo0 | @AASCTF | @AASCTF